# ការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

# ផ្នែក 4

# ការធ្វើឧបាស្រ័យ

# សេចក្ដីពន្យល់បន្ថែម

ថ្ងៃទី 25 ខែមេសា ឆ្នាំ2018

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់

MAEDA Yuta

- Slide 4

នៅក្នុងការរឹបអូសជាបណ្ដោះអាសន្ន ឬ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ បញ្ហាគឺត្រូវរក្សាភាពសម្ងាត់ ដូច្នេះ ប្រសិនបើតុលាការបានចេញដីកាសម្រេចរក្សាការពារដោយផ្អែកតាមពាក្យសុំរបស់ម្ចាស់បំណុល ជាទូទៅតុលាការមិនទុកឱកាសឲ្យកូនបំណុលធ្វើការអះអាង ឬ បញ្ជាក់ភស្តុតាងទេ។ ប្រសិនបើគិតតាមគំនិតនេះ មានន័យថា ការពិនិត្យទៅលើការចេញដីកាសម្រេចនោះសាជាថ្មីម្តងទៀត មុនពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺត្រូវធ្វើឡើងនៅសាលាដំបូងនៃការជំនុំជម្រះលើកទី១ នោះដដែល។

ចំពោះអំឡុងពេលដែលអាចដាក់ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ពុំមានចែងនៅក្នុងមាត្រាណាមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ប៉ុន្តែ ការតវ៉ាចំពោះការរក្សាការពារ គឺជានីតិវិធីដែលវិវាទអំពីភាពត្រឹមត្រូវឬមិនត្រឹមត្រូវចំពោះការដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ហើយពុំមានពាក់ព័ន្ធទៅនឹងការអនុវត្តដីកាសម្រេចរក្សាការពារទេ ដូច្នេះហើយ ជាគោលការណ៍ ដរាបណាដីកាសម្រេចរក្សាការពារនៅមានសុពលភាព គេយល់ឃើញថា ពាក្យសុំតវ៉ាចំពោះការរក្សាការពារអាចធ្វើឡើងនៅពេលណាក៏បាន។ ប៉ុន្តែ ជាធម្មតា ការតវ៉ាចំពោះការរក្សាការពារ គឺជាការធ្វើឧបាស្រ័យដោយផ្ទាល់ចំពោះដីកាសម្រេចរក្សាការពារ ហេតុនេះ មិនអាចដាក់ពាក្យសុំតវ៉ាច្រើនដងបាននោះទេ។

- Slide 5

ចំពោះការរឹបអូសជាបណ្ដោះអាសន្ន ឬ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ តុលាការនឹងចេញដីកាសម្រេចដោយគ្រាន់តែផ្អែកតាមពាក្យសុំពីម្ចាស់បំណុលតែប៉ុណ្ណោះ ហើយគេគិតថា ការតវ៉ាចំពោះការរក្សាការពារគឺជាឱកាសដែលតុលាការចាប់ផ្តើមស្តាប់ការអះអាងពីកូនបំណុលជាលើកដំបូង ហេតុនេះហើយ តុលាការចាំបាច់ត្រូវធ្វើការសម្រេចសេចក្តីដោយស្តាប់នូវការអះអាងរបស់ភាគីទាំងពីរឲ្យបានច្បាស់លាស់។

ការតវ៉ាចំពោះការរក្សាការពារ គឺជានីតិវិធីដែលតុលាការធ្វើការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវនៃការចេញដីកាសម្រេចរក្សាការពារ បន្ថែមពីលើដំណាក់កាលនៃពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ។ ហេតុនេះហើយ ចំណុចដែលត្រូវអះអាង និង បន្ទុកក្នុងការធ្វើសេចក្តីបញ្ជាក់ដំបូង គឺមិនខុសគ្នាទៅនឹងពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារនោះទេ ដូច្នេះ ម្ចាស់បំណុលចាំបាច់ត្រូវតែធ្វើការអះអាង និង បញ្ជាក់ភស្តុតាងអំពីភាពចាំបាច់នៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ ។

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៥៣ ដើម្បីបញ្ចប់ការវិនិច្ឆ័យ តុលាការត្រូវចេញដីកាសម្រេចអំពីថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ឬ ចាំបាច់ត្រូវប្រកាសអំពីការបញ្ចប់ការវិនិច្ឆ័យនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។ មាត្រានេះ គឺជាបញ្ញត្តិដែលបានចែងដើម្បីការពារនូវការមិនបានដឹងជាមុនរបស់ភាគី។

- Slide 6

លក្ខខណ្ឌនៃការផ្អាកការអនុវត្តរក្សាការពារគឺ មានសេចក្តីបញ្ជាក់ដំបូងអំពី ៖ ទី១ ស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង ទី២ ការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ។ ឧទាហរណ៍ជាក់ស្តែងដូចជា ៖ ទី ១ ត្រូវបានគេទទួលស្គាល់ថា មានស្ថានភាពដែលច្បាស់ថា អត្ថិភាពនៃភាពចាំបាច់នៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ឬ អត្ថិភាពនៃភាពចាំបាច់នៃការរក្សាការពារអាចបដិសេធបាន និង ទី២ ត្រូវបានគេទទួលស្គាល់ថា ការទទួលបានសំណងជាប្រាក់នៅពេលបន្ទាប់ មិនអាចធ្វើបដិទាននូវការខូចខាតមកវិញបាន ឬ ក្នុងករណីដែលធ្វើការប្រៀបធៀបរវាងទំហំនៃការខូចខាត និងលទ្ធភាពទ្រព្យធនរបស់ម្ចាស់បំណុល ឃើញថា សំណងជាទឹកប្រាក់មិនអាចសងបាន ឬ ករណីដែលប្រហាក់ប្រហែលគ្នានេះ។ ម្យ៉ាងវិញទៀត ដើម្បីទទួលស្គាល់នូវពាក្យសុំផ្អាកការអនុវត្តរក្សាការពារបាន តុលាការចាំបាច់ត្រូវបង្គាប់ឲ្យដាក់ប្រាតិភោគ។

- Slide 7

នៅប្រទេសជប៉ុន ទាក់ទងនឹងដីកាសម្រេចចំពោះពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ តុលាការសរសេរសំអាងហេតុប្រហាក់ប្រហែលទៅនឹងសាលក្រមដែរ ដោយមិនគិតពីសេចក្តីសន្និដ្ឋាននៃដីកាសម្រេចនោះទេ។

- Slide 8

អានុភាពនៃដីកាសម្រេចរក្សាការពារ មានបន្តរហូតដល់ពេលដែលដីកាសម្រេចលុបចោលនូវដីកាសម្រេចរក្សាការពារចូលជាស្ថាពរ។ ដូច្នេះហើយ វាគឺជាផលប្រយោជន៍សម្រាប់ម្ចាស់បំណុល។ ប្រសិន "ដីកាសម្រេចលុបចោលនូវដីកាសម្រេចរក្សាការពារ" ត្រូវបានលុបចោលដោយតុលាការនៃបណ្តឹងជំទាស់ជាលទ្ធផល ដីកាសម្រេចរក្សាការពារត្រូវបានរក្សានៅបន្ត ហើយដោយហេតុថា មានវិធានដូចខាងលើនេះហើយទើបអាចការពារនូវការចាត់ចែងកម្មវត្ថុដោយកូនបំណុល នៅក្នុងដំណាក់កាលបណ្តឹងជំទាស់បាន។

ឧទាហរណ៍នៃឃ្លាថា " បើយល់ឃើញថា ចាំបាច់ពិសេស" គឺមានដូចជា៖ នៅក្នុងដីកាសម្រេចរក្សាការពារដើមបង្ហាញច្បាស់ថាការបកស្រាយច្បាប់ធ្វើឡើងដោយមានការភាន់ច្រឡំជាអាទិ៍ ឬ ករណីដែលមានភាពច្បាស់លាស់ថា បើទោះបីជាបណ្តឹងជំទាស់ត្រូវបានធ្វើឡើងក៏ដោយ ក៏ពុំមានការផ្លាស់ប្តូរនូវសេចក្តីសន្និដ្ឋានក្នុងដីកាសម្រេច ឬ នៅពេលដែលមានការបារម្ភថា នឹងធ្វើឲ្យកូនបំណុលធនក្ស័យដោយសារតែការបន្តនូវការអនុវត្តរក្សាការពារ ។

- Slide １０

ដោយសារតែនីតិវិធីនៃការតវ៉ាចំពោះការរក្សាការពារ ត្រូវនឹងពាក្យថា "ការសម្រេចសេចក្តីដើម្បីបញ្ចប់រឿងក្តី" នៅថ្នាក់នៃការជម្រះក្តីនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦៥ កថាខណ្ឌទី១) ដូច្នេះ ត្រូវកំណត់អំពីបន្ទុកនៃសោហ៊ុយសម្រាប់នីតិវិធី។

- Slide 1 1

ការតវ៉ាចំពោះការរក្សាការពារ គឺជាការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ ហើយត្រូវបានធ្វើឡើងដោយយកមូលហេតុអំពីនត្ថិភាពនៃលក្ខខណ្ឌក្នុងការរក្សាការពារតាំងពីដំបូង។ ពោល ការតវ៉ាចំពោះការរក្សាការពារ គឺជាការជំនុំជម្រះបន្តលើពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ។ ដូច្នេះហើយ តុលាការត្រូវតែលើកឡើងអំពីការសម្រេចសេចក្ដីចំពោះពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ប្រសិនបើត្រូវលុបចោលដីកាសម្រេចរក្សាការពារ។

- Slide 1 2

ការលុបចោលនូវការរក្សាការពារ គឺជាវិធីជួយសង្គ្រោះដល់កូនបំណុលដោយធ្វើការលុបចោលនូវដីកាសម្រេចរក្សាការពារក្រោយពីតុលាការបានចេញដីកាសម្រេចរក្សាការពារ ផ្អែកលើស្ថានភាពដែលបានកើតឡើង ឬ ដែលបានបញ្ជាក់ច្បាស់។

ក្រោយពីតុលាការបានចេញដីកាសម្រេចរក្សាការពាររួចហើយ ប្រសិនបើគ្មានភាពចាំបាច់នៃការបន្តអត្ថិភាពនៃដីកាសម្រេចនេះតទៅទៀតទេ ចាំបាច់ត្រូវលុបចោលដីកាសម្រេចនេះដើម្បីកូនបំណុល។ ហេតុនេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានបង្កើតនូវនីតិវិធីដើម្បីលុបចោលនូវដីកាសម្រេចរក្សាការពារ ផ្អែកតាមពាក្យសុំរបស់កូនបំណុល ប្រសិនបើគេបានទទួលស្គាល់ថា មិនមានភាពចាំបាច់ក្នុងការបន្តអត្ថិភាពនៃដីកាសម្រេចរក្សាការពារ ស្របតាមប្រភេទណាមួយដែលបានកំណត់ ។

- Slide 1 3

ការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី គឺជាការចាត់ចែងជាបណ្ដោះអាសន្នរហូតដល់បណ្ដឹងអង្គសេចក្ដី ហើយប្រសិនបើបណ្ដឹងអង្គសេចក្ដីមិនត្រូវបានដាក់ទេ កូនបំណុលនឹងត្រូវទទួលរងជាបន្តនូវអានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្ន។ ប៉ុន្តែ នៅក្រោយពេលដែលតុលាការបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នរួចហើយ ម្ចាស់បំណុលត្រូវតែដាក់ពាក្យបណ្ដឹងអង្គសេចក្ដីឲ្យបានឆាប់រហ័ស ប្រសិនបើមិនធ្វើដូច្នោះទេ វានឹងក្លាយទៅជាការប្រើប្រាស់សិទ្ធិដោយបំពាន។ ដោយសារតែមូលហេតុនេះហើយ ទើបគេទទួលស្គាល់នូវប្រភេទនៃការលុបចោលការរក្សាការពារទាំងនេះ។

ចំពោះពាក្យថា "តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ" ក្នុងករណីដែលសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចរក្សាការពារ បន្ទាប់មកសាលាឧទ្ធរណ៍បានលើកចោលនូវបណ្ដឹងជំទាស់ ដូច្នេះគេយល់ថា ដីកាសម្រេចរក្សាការពារដែលសាលាដំបូងរាជធានីភ្នំពេញបានចេញនៅតែមាន ហេតុនេះហើយ សាលាដំបូងរាជធានីភ្នំពេញ គឺជា "តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ"។ ផ្ទុយទៅវិញ ប្រសិនបើសាលាឧទ្ធរណ៍ជាអ្នកចេញដីកាសម្រេចរក្សាការពារ ឬ សាលាឧទ្ធរណ៍បានផ្លាស់ប្ដូរនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារនៃការជំនុំជម្រះដើម នោះសាលាឧទ្ធរណ៍គឺជា "តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ"។

នៅពេលដែលតុលាការចេញដីកាសម្រេចផ្អែកតាមមាត្រា ៥៥៧ កថាខណ្ឌទី១ ពុំចាំបាច់ពិនិត្យមើលថា បណ្ដឹងអង្គសេចក្ដីកំពុងស្ថិតនៅក្រោមសមត្ថកិច្ចតុលាការនោះដែរ ឬអត់នោះទេ ។

ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់របស់ដីកាសម្រេចផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៥៧ កថាខណ្ឌទី១ មានដូចតទៅ ៖ " បង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តីមកតុលាការដែលមានសមត្ថកិច្ច ហើយត្រូវដាក់ឯកសារដែលបញ្ជាក់អំពីការដាក់នោះមកតុលាការនេះ ហើយនៅពេលដែលបានដាក់ពាក្យបណ្តឹងអង្គសេចក្តីរួចរាល់ហើយ ត្រូវដាក់ឯកសារដែលបញ្ជាក់អំពីសមត្ថកិច្ចដែលបណ្តឹងត្រូវស្ថិតនៅក្រោម មកតុលាការនេះក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចនេះ។"

ចំពោះ "ការដាក់ពាក្យបណ្តឹងអង្គសេចក្តី" ដែលចាំបាច់ត្រូវធ្វើឡើងដោយម្ចាស់បំណុល ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តីវិញនោះ ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្មក៏ចាត់ទុកថាជាការដាក់ពាក្យបណ្តឹងអង្គសេចក្តីដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៥៧ កថាខណ្ឌទី ៥) ។ ប៉ុន្តែ បើនីតិវិធីមជ្ឈត្តកម្មបានបញ្ចប់ដោយមិនបានកំណត់អំពីទំនាក់ទំនងសិទ្ធិទេ ចាំបាច់ត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តីក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងដីកាសម្រេចគិតចាប់ពីថ្ងៃបញ្ចប់នីតិវិធីមជ្ឈត្តកម្ម (មាត្រាដដែល កថាខណ្ឌទី៦)។ យ៉ាងណាមិញ ចំពោះនីតិវិធីផ្សេងក្រៅពីនីតិវិធីមជ្ឈត្តកម្ម អាចចាត់ទុកថាដូចគ្នានឹង "ការដាក់ពាក្យបណ្តឹងអង្គសេចក្តីដែរ" ឬទេ នោះគឺជាចំណុចដែលត្រូវធ្វើការវិនិច្ឆ័យថា តើនីតិវិធីនោះ គឺជានីតិវិធីចុងក្រោយដើម្បីកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារដែរទេ?

- Slide 14

ទោះបីជាម្ចាស់បំណុលចាញ់ក្តីនៅក្នុងបណ្តឹងអង្គសេចក្តីក៏ដោយ ក៏មិនមែនមានន័យថាអានុភាពនៃដីកាសម្រេចនឹងត្រូវបាត់បង់ភ្លាមៗនោះទេ ដូច្នេះហើយ កូនបំណុលត្រូវដាក់ពាក្យសុំលុបចោលការរក្សាការពារ។ ម្យ៉ាងវិញទៀត ប្រសិនបើមូលហេតុនៃការចាញ់ក្តីដោយសារតែលក្ខខណ្ឌមិនទាន់ត្រូវបានបំពេញ ឬ ការកំណត់ពេលមិនទាន់មកដល់ នោះមិនមែនមានន័យថា អត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារត្រូវបានតុលាការបដិសេធនោះទេ ដូច្នេះហើយ មិនមែនមានន័យថាដីកាសម្រេចរក្សាការពារនឹងត្រូវបានលុបចោលដោយផ្អែកលើមូលហេតុទាំងនោះទេ។

ទោះបីជាពាក្យសុំលុបចោលនូវការរក្សាការពារដោយយកមូលហេតុនៃការផ្លាស់ប្តូរស្ថានភាព ត្រូវបានលើកចោលម្តងរួចហើយក៏ដោយ ប្រសិនបើក្រោយពេលនោះ មានស្ថានភាពថ្មីកើតឡើង គឺមានតែត្រូវធ្វើការដាក់ពាក្យសុំលុបចោលនូវការរក្សាការពារម្តងទៀតដោយផ្អែកលើស្ថានភាពនោះ។ ប៉ុន្តែ ប្រសិនបើពាក្យសុំលុបចោលនូវការរក្សាការពារដែលធ្វើឡើងម្តងទៀតនោះបានយកមូលហេតុដដែលដូចគ្នាទៅនឹងពាក្យសុំដែលត្រូវបានតុលាការលើកចោលរួចហើយនោះ តុលាការត្រូវលើកចោលដោយផ្អែកលើមូលហេតុថា វាមានភាពផ្ទុយទៅនឹងគោលការណ៍សុចរិត និង ស្មោះត្រង់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤ )។ ម្យ៉ាងវិញទៀត ដោយសារតែការលុបចោលនូវការរក្សាការពារ គឺជានីតិវិធីនៃដីកាសម្រេច ហេតុនេះហើយ មិនមានអានុភាពនៃអាជ្ញាអស់ជំនុំទេ ។

- Slide15

ឧទាហរណ៍ចំពោះលក្ខខណ្ឌដែលបានលើកឡើងថា "មានការបារម្ភថា ការខូចខាតដែលមិនអាចសងបាននឹងកើតមានឡើងដោយសារតែដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន គឺៈ ក្នុងករណីដែលទទួល

វេងនូវការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការធ្វើអាជីវកម្មទំនិញសំខាន់ ដែលជាហេតុធ្វើឲ្យការបន្តមុខជំនួញរបស់កូនបំណុលគ្មានលទ្ធភាពបន្តទៅទៀត ឬ ធ្វើឲ្យជួបប្រទះការលំបាក។ ម្យ៉ាងវិញទៀតចំពោះឧទាហរណ៍នៃពាក្យថា " មានស្ថានភាពពិសេសផ្សេងទៀត" គឺ៖ នៅពេលដែលការធានាជាប្រាក់ចំពោះការអនុវត្តសិទ្ធិដែលនឹងត្រូវបានរក្សាការពារមានភាពគ្រប់គ្រាន់ ពោលគឺមានន័យថា មូលដ្ឋាននៃសិទ្ធិ ឬ មូលដ្ឋានផ្សេងទៀតរបស់ម្ចាស់បំណុល ជាសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ហើយអាចទទួលការជម្រះនូវសិទ្ធិដែលនឹងត្រូវបានរក្សាការពារនឹងត្រូវដោយការសងបាន (ការចាត់ចែងជាបណ្ដោះអាសន្នចំពោះសិទ្ធិដែលនឹងត្រូវបានរក្សាការពារដែលមានកម្មវត្ថុជាសិទ្ធិប្រាតិភោគជាអាទិ៍ )។

ប្រភេទនៃការលុបចោលការរក្សាការពារនេះ មានលក្ខខណ្ឌតឹងរ៉ឹង ហើយចំពោះចំនួននៃប្រាក់ដែលត្រូវដាក់ប្រាតិភោគក៏ច្រើនខ្លាំង ហេតុនេះ នៅប្រទេសជប៉ុន គេមិនសូវយកមកប្រើនោះទេ។

- Slide１６

តួយ៉ាង នៅក្នុងការវិនិច្ឆ័យអំពីការលុបចោលនូវការរក្សាការពារ ចាំបាច់ត្រូវធ្វើឡើងដោយឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។ ប៉ុន្តែ ប្រសិនបើការលុបចោលនូវការរក្សាការពារបានធ្វើឡើងដោយសារតែការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាអាទិ៍ នៅពេលដែលធ្វើការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹងនៅក្នុងដំណាក់កាលទី១ ជាអាទិ៍ មិនចាំបាច់ធ្វើដូចខាងលើនោះទេ។ ប៉ុន្តែ នៅពេលដែលចេញដីកាសម្រេចលុបចោលនៅក្នុងដំណាក់កាលទី២វិញ ចាំបាច់ត្រូវតែឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍។

- Slide１７

ពាក្យសុំលុបចោលនូវការរក្សាការពារ គឺជាពាក្យសុំដែលយកមូលហេតុថា ដីកាសម្រេចរក្សាការពារមានភាពមិនត្រឹមត្រូវដោយសារតែមានស្ថានភាពដែលកើតនៅក្រោយពេលចេញដីកាសម្រេចនោះ គឺមិនមែនជាពាក្យសុំដែលយកបញ្ហាអំពីនត្ថិភាពនៃលក្ខខណ្ឌនៅពេលចេញដីកាសម្រេចរក្សាការពារមកធ្វើជាមូលហេតុទេ។ ការលុបចោលនូវការរក្សាការពារនេះ ពុំមានភាពចាំបាច់ក្នុងការវិនិច្ឆ័យទៅលើពាក្យសុំរក្សាការពារនៅពេលដែលធ្វើការលុបចោលនូវការរក្សាការពារទេ ដោយសារតែវាគឺជា ពាក្យសុំរក្សាការពារមានភាពឯករាជ្យ ហើយគឺជានីតិវិធីដាច់ដោយឡែក។

- Slide１８

នៅពេលដែលចេញដីកាសម្រេចលុបចោលនូវការរក្សាការពារ ផ្អែកតាមមាត្រា៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាំបាច់ត្រូវតែបង្គាប់ឲ្យដាក់ប្រាតិភោគ ដើម្បីធ្វើជាលក្ខខណ្ឌ។

សូមអរគុណ